# អង្គជំនុំជម្រះសាលាដំបូងស្តាប់សក្ខីកម្មរបស់សាក្សីពីររូប និងកត់សម្គាល់ពីការផ្លាស់ប្តូរនៅក្នុងនីតិវិធី

*ដោយ ឆាល ចេកសាន់*

*ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩*

*ប្រែសម្រួលដោយ ខែន សុខស្រីនិត*

គក ស្រស់ អតីតឆ្មាំយាមគុកទួលស្លែង (មន្ទីរស-២១) បានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសារជាថ្មីម្តងទៀតនៅក្នុងថ្ងៃនេះ ដើម្បីចែករំលែកបទពិសោធន៍របស់គាត់ក្នុងនាមជាអ្នកនៅក្រោមបង្គាប់របស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ។

## ទស្សនិកជនសម្តែងនូវប្រតិកម្មយ៉ាងខ្លាំងចំពោះសក្ខីកម្មរបស់សាក្សី

នៅពេលដែលភាគីទាំងអស់បានសួរសំណួរទៅកាន់ គក ស្រស់ ទស្សនិកជនដែលអង្គុយនៅសាលសាធារណៈត្រូវបានរំឭកពីទុក្ខលំបាកវេទនាជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលបានកើតមានឡើង កាលពីសាមសិបឆ្នាំមុន ។ ខណៈពេលដែលត្រូវបានសួរពីព័ត៌មានទាក់ទិននឹងដំណើរប្រតិបត្តិការរបស់គុកទួលស្លែង និងទង្វើរដែលប្រព្រឹត្តមកលើអ្នកទោស គក ស្រស់ បានទទូចនិយាយថា គាត់មានការចងចាំមិនសូវល្អប៉ុន្មានទេ ដូច្នេះគាត់មិនអាចផ្តល់នូវសក្ខីកម្មដែលគួរឲ្យជឿជាក់ដល់តុលាការបានឡើយ ។ ទស្សនិកជនបានសម្តែងនូវមន្ទិលសង្ស័យ ដោយបង្ហាញនូវភាពមិនជឿទុកចិត្តជាច្រើនលើក នៅពេលដែល គក ស្រស់ អះអាងថា គាត់មិនបានចាំនូវព័ត៌មានសំខាន់ៗមួយចំនួនដូចជា ឈ្មោះអ្នកគ្រប់គ្រងមន្ទីរស-២១ ហើយគាត់មិនចាំសូម្បីថា តើគាត់បានជួយកប់សាកសពអ្នកទោសក្រោយពីមនុស្សទាំងនោះត្រូវបានសម្លាប់រួចហើយក៏ដោយ ។

គក ស្រស់ បានបដិសេធថា គាត់មិនដឹងពីហេតុការណ៍អាក្រក់ៗដែលកើតមានឡើងនៅមន្ទីរស-២១ ឡើយ បើទោះបីជាហេតុការណ៍ទាំងនោះត្រូវបានចងក្រងទុកជាឯកសារដោយតុលាការក៏ដោយ ។ ការបដិសេធនេះបានធ្វើឲ្យទស្សនិកជនកាន់តែមានប្រតិកម្មខ្លាំងឡើង ។ ឧទាហរណ៍ គក ស្រស់ បាននិយាយថា គាត់មិនដែលឃើញអ្នកទោសស្រី ឬក្មេង មិនឃើញការនាំយកអ្នកទោសជាក្រុមចេញពី

បន្ទប់ឃុំឃាំង ហើយគាត់ក៏មិនដែលឮពីការសម្លាប់អ្នកទោសនៅវាលពិឃាតបឹងជើងឯកដែរ ។ បន្ទាប់ពីការបដិសេធជាបន្តបន្ទាប់ ទស្សនិកជនបានបញ្ចេញសម្លេងរអ៊ូរទាំយ៉ាងខ្លាំងចំពោះសក្ខីកម្មរបស់ គក ស្រស់ ។

ចៅក្រម ឡាវ៉ែន ទំនងជាមានមន្ទិលសង្ស័យដូចទស្សនិកជនដែរ ។ លោកចៅក្រមបានឆ្លៀតឱកាសរំឭកសាក្សីពីកាតព្វកិច្ចរបស់ខ្លួនដែលត្រូវនិយាយការពិត ។ បន្ទាប់មកទៀត ចៅក្រម ឡាវ៉ែន បានសួរថា តើ គក ស្រស់ ភ័យខ្លាចមែនដែរឬទេ ។ ការសួរបែបនេះបានឆ្លុះបញ្ចាំងពីមន្ទិលសង្ស័យមួយដែលថា គក ស្រស់ មិនចង់និយាយដោយសារតែភាពភ័យខ្លាចថាគាត់អាចនឹងត្រូវបានកាត់ទោស ឬដោយសារតែគាត់មានអារម្មណ៍ថាខ្លាច ឌុច ។ គក ស្រស់ បានបដិសេធថា គាត់មិនខ្លាចនឹងធ្វើសក្ខីកម្មដោយនិយាយពីការពិតទេ ហើយគាត់បានសង្កត់ធ្ងន់ថា គាត់បានបាត់បង់ការចងចាំច្រើនណាស់ ។

## ដើមបណ្តឹងរដ្ឋប្បវេណីផ្លាស់ប្តូរនីតិវិធីសួរសំណួរ

ក្នុងរយៈពេលផ្អាកដំណើរការសួរសំណួរទៅកាន់សាក្សី ចៅក្រមបានធ្វើការដោះស្រាយនឹងសំណើចំនួនពីរដែលស្នើឡើងដោយសហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ស៊ីលឃី ស្តូតហ្ស៊ីនស្គី ដែលធ្វើឡើងកាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ ។ កាលពីថ្ងៃនោះ សហព្រះរាជអាជ្ញា វីលៀម ស្មីត បានស្នើថា ចៅក្រមគួរតែកុំអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីសួរសំណួរទៅកាន់ជនជាប់ចោទខណៈពេលដែលកំពុងតែសួរសាក្សី ។ ដោយសារតែព្រួយបារម្ភចំពោះរយៈពេលកំណត់ដែលមានត្រឹមតែដប់ប្រាំនាទីរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដើម្បីសួរសំណួរសាក្សីនោះ ស្តូតហ្ស៊ីនស្គី បានស្នើសុំថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានអនុញ្ញាតឲ្យប្រគល់ជូនសំណួរ ដែលភាគីរបស់ខ្លួនមិនអាចសួរសាក្សីបានទៅឲ្យចៅក្រម ។ ការធ្វើដូច្នេះអាចអនុញ្ញាតឲ្យចៅក្រមសម្រេចថា តើសំណួរបែបនេះអាចសួរទៅកាន់សាក្សីបានដែរឬទេ ។ ចៅក្រមបានជំទាស់នឹងសំណើទាំងពីរនេះដោយផ្តល់ជាការពន្យល់បកស្រាយយ៉ាងខ្លីចំពោះសំណើរបស់សហព្រះរាជអាជ្ញា វីលៀម ស្មីត ប៉ុន្តែបានពន្យល់យ៉ាងច្បាស់ពីមូលហេតុជំទាស់នឹងសំណើរបស់មេធាវី ស្តូតហ្ស៊ីនស្គី ដោយអះអាងថា ការទទួលយកសំណួរទាំងនោះអាចបណ្តាលឲ្យដំណើរនីតិវិធីប្រព្រឹត្តទៅដោយគ្មានប្រសិទ្ធិភាព ។

ក្រោយពីការជំទាស់នឹងសំណើទាំងពីររួចមក ចៅក្រមនៅតែកត់សម្គាល់ពីការផ្លាស់ប្តូរនីតិវិធីរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលចាប់ផ្តើមធ្វើការជាក្រុមតែមួយក្នុងអំឡុងពេលសួរសំណួរសាក្សី ។ កាលពីមុន មេធាវីដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗសួរសំណួរទៅកាន់សាក្សីរៀងៗខ្លួន ដែលការធ្វើដូច្នេះបណ្តាលឲ្យកើតមានជាការសួរសំណួរដដែលៗ ។ ប៉ុន្តែសម្រាប់ថ្ងៃនេះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់បានដាក់សំណួររបស់ខ្លួនបញ្ចូលគ្នានៅក្នុងបញ្ជីតែមួយ និងបានជ្រើសរើសមេធាវីម្នាក់ធ្វើជាតំណាងដើម្បីសួរសំណួរទាំងអស់នោះទៅកាន់សាក្សី ។ ការអនុវត្តបែបនេះបានអនុញ្ញាតឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដាក់ពេលវេលារបស់ខ្លួនរួមគ្នា និងប្រើប្រាស់ពេលវេលាទាំងនោះកាន់តែមានប្រសិទ្ធិភាពជាងមុន ។ បន្ថែមលើនេះ ការធ្វើដូច្នេះបានជួយប្រឆាំងនឹងមតិរិះគន់ ដែលថាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីតែងតែបង្កឲ្យមានការកក់ស្ទះដែលមិនចាំបាច់ដល់ដំណើរការនីតិវិធី ។

## អង្គជំនុំជម្រះបង្ហាញសាក្សីបន្ទាប់

ក្នុងដំណើរការនីតិវិធីនាពេលចុងក្រោយសម្រាប់ថ្ងៃនេះ ចៅក្រមបានបង្ហាញសាក្សីបន្ទាប់គឺ សួស ធី អាយុ៥៨ឆ្នាំ ។ ក្រោយពីបានចូលបំរើបដិវត្តន៍ដោយធ្វើជាកងឈ្លបក្នុងឆ្នាំ១៩៧១ និងបានបំរើនៅអង្គភាពកងយោធាផ្សេងៗអស់រយៈពេលជាច្រើនឆ្នាំមក សួស ធី ត្រូវបានចាត់តាំងឲ្យមកធ្វើជាឆ្មាំយាមគុកនៅមន្ទីរស-២១ក្នុងឆ្នាំ១៩៧៨ ។ ខណៈពេលបំរើការងារនៅមន្ទីរស-២១ សួស ធី មានតួនាទីរក្សាបញ្ជីឈ្មោះអ្នកទោសដែលចូលថ្មី និងអ្នកទោសដែលនាំចេញទៅសម្លាប់ចោល ។ លើសពីនេះ សួស ធី ក៏មានតួនាទីកត់ត្រាប្រវត្តិរូបអ្នកទោស និងគ្រប់គ្រងកិច្ចការតាមបន្ទប់ឃុំឃាំង ។ សួស ធី បាននៅធ្វើការឲ្យមន្ទីរស-២១រហូតដល់កងទ័ពវៀតណាមចូលមកដល់ទីក្រុងភ្នំពេញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

ផ្ទុយពី គក ស្រស់ ដែលធ្វើសក្ខីកម្មដោយព្យាយាមមិននិយាយការពិត សួស ធី ហាក់បីដូចជាមានឆន្ទះក្នុងការនិយាយការពិត ដោយផ្អែកលើការចងចាំរបស់គាត់ទាក់ទិននឹងដំណើរប្រតិបត្តិការរបស់មន្ទីរស-២១ ។ ខណៈពេលធ្វើការឆ្លើយតបនឹងសំណួររបស់ប្រធានចៅក្រម និល ណុន, សួស ធី បានផ្តល់នូវការពន្យល់រៀបរាប់ដ៏លម្អិតស្តីពីដំណើរការគ្រប់គ្រងអ្នកទោសដែលចេញចូលមន្ទីរស-២១ ដល់អង្គជំនុំជម្រះទាំងមូល ។

នៅពេលដែលអ្នកទោសបានមកដល់មន្ទីរស-២១ សួស ធី បានកត់ឈ្មោះ និងសរសេរប្រវត្តិរូបអ្នកទោសទាំងនោះ ហើយបន្ទាប់មកទៀតគាត់ក៏បែងចែកអ្នកទោសឲ្យចូលទៅកាន់បន្ទប់ឃុំឃាំងរបស់គេរៀងៗខ្លួន។ បន្ទាប់ពីនេះ សួស ធី បានបញ្ជូនអ្នកទោសទាំងនោះទៅកាន់បន្ទប់ថតរូបដើម្បីទុកជាឯកសារចំណាំ។ ក្រោយពីថតរូប អ្នកទោសត្រូវបានចងភ្នែក ដាក់ខ្នោះ និងនាំទៅកាន់បន្ទប់ឃុំឃាំង។ ខណៈពេលដែលត្រូវបានសួរថា តើឈ្មោះនិងប្រវត្តិរូបរបស់កូនក្មេងត្រូវបានកត់ត្រាដែរឬទេ? សួស ធី បាននិយាយថា មិនមានការកត់ត្រាឈ្មោះនិងប្រវត្តិរូបរបស់កូនក្មេងទេ ព្រោះជាទូទៅ កូនក្មេងបានមកកាន់មន្ទីរស-២១ជាមួយនឹងឪពុកម្តាយរបស់គេ ហើយកូនក្មេងទាំងនោះត្រូវបានសម្លាប់ភ្លាមៗបន្ទាប់ពីឪពុកម្តាយរបស់គេត្រូវបានឃុំឃាំង។

នៅពេលដែលការសួរចម្លើយអ្នកទោសបានចាប់ផ្តើមដំណើរការ សួស ធី បានរៀបរាប់ថា បញ្ជីឈ្មោះអ្នកទោសដំបូងគេនឹងត្រូវបញ្ជូនមកឲ្យគាត់ដើម្បីពិនិត្យមើលឈ្មោះអ្នកទោសនីមួយៗ ហើយកត់ត្រាពីទីតាំងបន្ទប់ឃុំឃាំងរបស់អ្នកទោសទាំងនោះ។ បន្ទាប់មកទៀត បញ្ជីឈ្មោះអ្នកទោសនេះត្រូវបានបញ្ជូនទៅឲ្យឆ្មាំយាមគុកផ្សេងទៀតដើម្បីនាំអ្នកទោសចូល។

ចុងក្រោយបង្អស់ ខណៈពេលដែលអ្នកទោសត្រូវបាននាំចេញពីបន្ទប់ឃុំឃាំង ដើម្បីយកទៅសម្លាប់ សួស ធី នឹងទទួលបានបញ្ជីឈ្មោះអ្នកទោសម្តងទៀត ហើយធ្វើការកត់ត្រាពីទីតាំងបន្ទប់ឃុំឃាំងរបស់អ្នកទោសទាំងនោះ រួចហើយក៏ប្រគល់បញ្ជីឈ្មោះទៅឲ្យឆ្មាំយាមគុកផ្សេងទៀតដើម្បីនាំអ្នកទោសចេញ។ បន្ទាប់មកទៀត អ្នកទោសត្រូវបាននាំមកខាងក្រៅក្បែររបងច្រកចេញមន្ទីរស-២១។ នៅទីនោះ សួស ធី នឹងពិនិត្យឈ្មោះអ្នកទោសសារជាថ្មីម្តងទៀតដើម្បីសរុបចំនួនអ្នកទោសដែលត្រូវយកទៅសម្លាប់ មុនពេលដែលអ្នកទោសទាំងនោះឡើងលើរថយន្តមួយ ដែលនាំអ្នកទោសទៅសម្លាប់នៅវាលពិឃាតបឹងជើងឯក។

ក្រោយពីប្រធានចៅក្រម និល ណុន បានបញ្ចប់សួរសំណួរសាក្សីរួចមក អង្គជំនុំជម្រះសាលាដំបូងបានផ្អាកដំណើរការនីតិវិធីត្រឹមនេះ។ សួស ធី នឹងបន្តធ្វើសក្ខីកម្មរបស់គាត់បន្ថែមទៀតនៅថ្ងៃស្អែកទី២៨ ខែកក្កដា ឆ្នាំ២០០៩។